**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរខណ្ឌ នៃខេត្តព្រះសីហនុទៅជាក្រុង និង ជាស្រុក

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និង ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៣៨៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការប្តូរក្រុងព្រះសីហនុទៅជាខេត្តព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១ .—**

ត្រូវបានប្តូរខណ្ឌ នៃខេត្តព្រះសីហនុ ទៅជាក្រុង និង ជាស្រុក ដូចខាងក្រោម :

- ខណ្ឌមិត្តភាព ទៅជា ក្រុងព្រះសីហនុ
- ខណ្ឌព្រៃនប់ ទៅជា ស្រុកព្រៃនប់
- ខណ្ឌស្ទឹងហាវ ទៅជា ស្រុកស្ទឹងហាវ។

**មាត្រា ២ .—**

ក្រុងព្រះសីហនុ មានសង្កាត់ ០៥ គឺ :

- សង្កាត់លេខ ១
- សង្កាត់លេខ ២
- សង្កាត់លេខ ៣
- សង្កាត់លេខ ៤
- សង្កាត់កោះរ៉ុង ។

**មាត្រា ៣ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកព្រៃនប់ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់ទឹកថ្លា ទៅជា ឃុំទឹកថ្លា
- សង្កាត់ទឹកល្អក់ ទៅជា ឃុំទឹកល្អក់
- សង្កាត់សាមគ្គី ទៅជា ឃុំសាមគ្គី
- សង្កាត់ជើងគោ ទៅជា ឃុំជើងគោ
- សង្កាត់វាលរេញ ទៅជា ឃុំវាលរេញ
- សង្កាត់សំរុង ទៅជា ឃុំសំរុង
- សង្កាត់អណ្តូងថ្ម ទៅជា ឃុំអណ្តូងថ្ម
- សង្កាត់ទួលទទឹង ទៅជា ឃុំទួលទទឹង
- សង្កាត់ព្រៃនប់ ទៅជា ឃុំព្រៃនប់
- សង្កាត់អូរឧកញ៉ាហេង ទៅជា ឃុំអូរឧកញ៉ាហេង
- សង្កាត់បឹងតាព្រហ្ម ទៅជា ឃុំបឹងតាព្រហ្ម
- សង្កាត់អូរជ្រៅ ទៅជា ឃុំអូរជ្រៅ
- សង្កាត់រាម ទៅជា ឃុំរាម
- សង្កាត់បិតត្រាង ទៅជា ឃុំបិតត្រាង ។

**មាត្រា ៤ .—**

ត្រូវបានប្តូរសង្កាត់ នៃស្រុកស្ទឹងហាវ ទៅជាឃុំ ដូចខាងក្រោម :

- សង្កាត់អូរត្រេះ ទៅជា ឃុំអូរត្រេះ
- សង្កាត់ទំនប់រលក ទៅជា ឃុំទំនប់រលក
- សង្កាត់កំពេញ ទៅជា ឃុំកំពេញ ។

**មាត្រា ៥ .—**

ត្រូវបានបញ្ចូលផ្ទៃដី និង ប្រជាពលរដ្ឋ ដែលបានកាត់មកពីឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

**មាត្រា ៦ .—**

ត្រូវបានបញ្ចូលផ្ទៃដី និង ប្រជាពលរដ្ឋ ដែលបានកាត់មកពីឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ឱ្យមកស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលឃុំស្ទឹងឆាយ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ។

**មាត្រា ៧ .—**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង និង ស្រុក នៃខេត្តព្រះសីហនុ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៨ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តព្រះសីហនុ អភិបាលក្រុង អភិបាលស្រុក និង ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ០៧ ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*